ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៦២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាព រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤២០/០១៨ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .–**

អនុក្រឹត្យនេះកំណត់អំពីសមាសភាព តួនាទី ភារកិច្ច សិទ្ធិអំណាច និងរបៀបរបបការងាររបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីពង្រឹងតួនាទី ការទទួលខុសត្រូវ និងការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម ការពារធនធានព្រៃឈើ ជលផល តំបន់ការពារធម្មជាតិ ការបង្ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសនានា នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .–**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរនិងអង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ក្រោមជាតិ។

**មាត្រា៣ .–**

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានសមាសភាពដូចខាងក្រោម៖

**ក. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត**

-អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធាន

| | |
|---|---|
| -អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| -ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត | អនុប្រធាន |
| -មេបញ្ជាការនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី ខេត្ត | អនុប្រធាន |
| -ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត | សមាជិក |
| -ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត | សមាជិក |
| -ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត | សមាជិក |
| -ប្រធានសាខាគយនិងរដ្ឋាករខេត្ត | សមាជិក |
| -ប្រធានសាខាពន្ធដារខេត្ត ខណ្ឌ | សមាជិក |
| -នាយករដ្ឋបាលសាលារាជធានី ខេត្ត | សមាជិក |
| -អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ | សមាជិក។ |

ខ- គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ

| | |
|---|---|
| -អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ | ប្រធាន |
| -អភិបាលរងនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| -អធិការនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ | អនុប្រធាន |
| -មេបញ្ជាការនៃមូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌ | អនុប្រធាន |
| -នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ | សមាជិក |
| -មេឃុំ ចៅសង្កាត់ | សមាជិក។ |

ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត អាចបន្ថែមប្រធានមន្ទីរនិងប្រធានអង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នដែលប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ ជាសមាជិកនៃគណៈបញ្ជាការឯកភាពរបស់ខ្លួន ស្របតាមស្ថានភាពជាក់ស្តែងនៃមូលដ្ឋាននីមួយៗ តាមការចាំបាច់។

ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចបន្ថែមប្រធានអង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នដែលប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ជាសមាជិកនៃគណៈបញ្ជាការឯកភាពរបស់ខ្លួន ស្របតាមស្ថានភាពជាក់ស្តែងនៃមូលដ្ឋាននីមួយៗ តាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា៤ ._**

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សម្របសម្រួលនិងចាត់វិធានការ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ការបង្ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសដែលពាក់ព័ន្ធនឹងអំពើភេរវកម្ម អំពើលួច ឆក់ប្លន់គ្រប់ប្រភេទ ការផលិត ការចែកចាយ



95

និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ បទល្មើសបច្ចេកវិទ្យាព័ត៌មាន រួមទាំងអំពើឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសសេដ្ឋកិច្ច អំពើអនាចារ ការជួញដូរស្ត្រីនិងកុមារ អំពើហិង្សាគ្រប់ប្រភេទ សកម្មភាពក្មេងទំនើង ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ អំពើបំផ្លិចបំផ្លាញធនធានព្រៃឈើ ជលផល តំបន់ការពារធម្មជាតិ និងបទល្មើសគ្រប់ប្រភេទផ្សេងទៀតដែលកើតមានឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

- ដឹកនាំ សម្របសម្រួល ដោះស្រាយការងារចរាចរណ៍ ចំណតយានយន្ត អនាម័យសាធារណៈ ការងារអគ្គិភ័យ សោភណភាពតាមទីសាធារណៈ និងរៀបចំសណ្ដាប់ធ្នាប់ របៀបរៀបរយផ្សេងទៀត
- ដោះស្រាយឱ្យបានទាន់ពេលវេលានូវបាតុភាពនានាពាក់ព័ន្ធនឹងសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ព្រមទាំងគ្រោះធម្មជាតិ ជំងឺរាតត្បាត និងស្ថានភាពអាសន្នផ្សេងៗទៀត ដែលកើតមានឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ដឹកនាំ សម្របសម្រួល និងចាត់ចែងការងារឆ្លើយតបទៅនឹងស្ថានភាពចាំបាច់ ដើម្បីធានាបាននូវភាពល្អប្រសើរនៃសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ដឹកនាំ ត្រួតពិនិត្យ និងជំរុញការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីឱ្យមានប្រសិទ្ធភាពខ្ពស់
- បំផុសនិងលើកកម្ពស់ការចូលរួមពីមន្ទីរ អង្គភាពពាក់ព័ន្ធ និងសហគមន៍មូលដ្ឋានក្នុងការរក្សាការពារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម ធនធានព្រៃឈើ ជលផល តំបន់ការពារធម្មជាតិ ការបង្ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- លើកកម្ពស់កិច្ចសហការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានភូមិសាស្ត្រជាប់គ្នា ដើម្បីរក្សាការពារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម ធនធានព្រៃឈើ ជលផល តំបន់ការពារធម្មជាតិ ការបង្ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសនានាដែលមានការពាក់ព័ន្ធក្នុងភូមិសាស្ត្ររួម
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៥ .-**

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានសិទ្ធិអំណាចនិងរបៀបរបបការងារដូចខាងក្រោម៖

- ក្នុងការអនុវត្តតួនាទីនិងភារកិច្ចដូចមានកំណត់ក្នុងមាត្រា៤នៃអនុក្រឹត្យនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវដឹកនាំ បញ្ជាកងកម្លាំងនគរបាលជាតិនិងកងរាជអាវុធហត្ថអាជ្ញាធរមានសមត្ថកិច្ច មន្ទីរ និងអង្គភាពពាក់ព័ន្ធនានា ដើម្បីចាត់វិធានការស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្នុងករណីចាំបាច់ គណៈបញ្ជាការឯកភាព អាចសម្របសម្រួល ប្រមូលផ្តុំកម្លាំងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ធ្វើអន្តរាគមន៍ ឬអាចរាយការណ៍ស្នើសុំអន្តរាគមន៍ពីរដ្ឋបាលថ្នាក់ជាតិ ក្នុងករណីដែលគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត មិនអាចដោះស្រាយបាន

- អនុប្រធានអចិន្ត្រៃយ៍ អនុប្រធាន និងសមាជិកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវស្ថិតក្រោមការគ្រប់គ្រង ដឹកនាំ ណែនាំ និងបញ្ជាផ្ទាល់ពីប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្នុងការគ្រប់គ្រងសភាពការណ៍និងចាត់ចែងការងារប្រចាំថ្ងៃ ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវប្រគល់សិទ្ធិជូនអនុប្រធានអចិន្ត្រៃយ៍ឱ្យដឹកនាំនិងសម្របសម្រួលកងកម្លាំងនគរបាលជាតិនិងកងរាជអាវុធហត្ថ អាជ្ញាធរមានសមត្ថកិច្ច មន្ទីរ និងអង្គភាពពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- អនុប្រធានអចិន្ត្រៃយ៍ អនុប្រធាន និងសមាជិកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តនូវរាល់ផែនការការងារនិងវិធានការដែលបានសម្រេចដោយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្នុងករណីដែលអនុប្រធានអចិន្ត្រៃយ៍ អនុប្រធាន និងសមាជិកណាម្នាក់ មិនអនុវត្ត ឬអសកម្ម ឬមានការធ្វេសប្រហែស ឬមិនទទួលខុសត្រូវនៅក្នុងការអនុវត្តផែនការការងារ ឬវិធានការ ឬការណែនាំរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួង ស្ថាប័នសាមី ដើម្បីមានវិធានការ
- អនុប្រធានអចិន្ត្រៃយ៍ អនុប្រធាន និងសមាជិកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវចូលរួមប្រជុំតាមការអញ្ជើញ និងអនុវត្តការងារតាមការណែនាំរបស់ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមី
- ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចអញ្ជើញប្រធានមន្ទីរ អង្គភាព ឬអ្នកពាក់ព័ន្ធផ្សេងៗទៀតឱ្យចូលរួមកិច្ចប្រជុំរបស់ខ្លួន តាមការចាំបាច់
- រាល់កិច្ចប្រជុំរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវជូនដំណឹងដល់អង្គភាពយោធាតាមឋានានុក្រមដែលស្ថិតនៅក្នុងមូលដ្ឋាននៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនោះ ដើម្បីចាត់តាំងអ្នកតំណាងរបស់ខ្លួនឱ្យចូលរួមក្នុងកិច្ចប្រជុំខាងលើ។ តំណាងអង្គភាពយោធាដែលត្រូវបានចាត់តាំងត្រូវចូលរួមក្នុងកិច្ចប្រជុំរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីក្ដាប់សភាពការណ៍ទូទៅនៅក្នុងមូលដ្ឋាននៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួន
- ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចស្នើសុំកិច្ចសហការពីអង្គភាពយោធាតាមឋានានុក្រមដែលមានមូលដ្ឋានក្នុងដែនដីរបស់ខ្លួន ក្នុងការជួយសង្គ្រោះនៅពេលមានគ្រោះធម្មជាតិ ជំងឺរាតត្បាត និងស្ថានភាពអាសន្នផ្សេងៗទៀត ឬក្នុងការបង្ក្រាបអំពើល្មើសដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខជាតិនិងសណ្ដាប់ធ្នាប់សាធារណៈ
- ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកោះប្រជុំជាសាមញ្ញយ៉ាងតិចរយៈពេល ១(មួយ)ខែម្ដង ដើម្បីបូកសរុបនិងវាយតម្លៃលទ្ធផលនៃការអនុវត្តការងាររបស់ខ្លួន និងដាក់ចេញនូវផែនការការងារនិងវិធានការបន្ត។ ក្នុងករណីចាំបាច់ ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចកោះប្រជុំជាវិសាមញ្ញ ដើម្បីដោះស្រាយការងារ ឬបញ្ហាសំខាន់ៗ ឬសភាពការណ៍ណាមួយដែលអាចប៉ះពាល់ដល់សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

- ក្នុងករណីចាំបាច់ដែលតម្រូវឱ្យមានការធានានូវការសម្ងាត់ក្នុងកិច្ចការសន្តិសុខ ប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានសិទ្ធិកោះប្រជុំ ដោយអញ្ជើញតែសមាជិកដែលពាក់ព័ន្ធនឹងកិច្ចការសន្តិសុខឱ្យចូលរួមប៉ុណ្ណោះ
- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរាយការណ៍អំពីលទ្ធផលនៃការអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនជូនក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមី
- គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរាយការណ៍ជាប្រចាំអំពីការអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនជូនគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តសាមី
- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវរាយការណ៍និង/ឬសុំយោបល់ដឹកនាំជាប្រចាំអំពីការអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនពីក្រសួង ស្ថាប័នពាក់ព័ន្ធ
- គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំអំពីការអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនជូនគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តសាមី
- គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវបូកសរុបធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចកោះប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត រួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា៦ .-**

គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានលេខាធិការដ្ឋាន ដើម្បីជួយការងារក្នុងគណៈបញ្ជាការឯកភាពរបស់ខ្លួន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៧ .-**

រាល់លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការអនុវត្តអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៨ .-**

អនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១ រោច ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្ដិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ